ក្រសួងសុខាភិបាល
ចូលមក ការិ.រៀបចំនិងឯកសារ
ថ្ងៃទី 1 ខែ 04 ឆ្នាំ 2025 ម៉ោង 8.40 នាទី
ចុះបញ្ជីលេខ 1427 ...ផ.ឃ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
ចូលមក នាយកដ្ឋាន[illegible] 4
ថ្ងៃទី 21 ខែ 05 ឆ្នាំ 2025 ម៉ោង [illegible] នាទី
ចុះបញ្ជីលេខ ១៣១ ស.ឥក

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ០៥ សរ**

## សារាចរ
## ស្តីពី
## ការកំណត់ និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ

ផ្អែកលើស្មូលនៃ**"យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១"** ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដែលផ្ដោតលើអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ រាជរដ្ឋាភិបាលបានកំណត់អភិក្រម **"រៀបចំផ្ទះឱ្យរៀបរយ"** និង **"ពង្រឹងជាជាងពង្រីក"** ដើម្បីជានាការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នឱ្យមានប្រសិទ្ធភាពខ្ពស់។

កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវសេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងសារាចរលេខ០៨ សរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការកែសម្រួលរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការរៀបចំមុខងារ និងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។ យោងតាមលទ្ធផលនៃការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងស្មារតីនៃកិច្ចប្រជុំលើកទី៣ របស់គណៈកម្មាធិការជាតិជំរុញការអនុវត្តជានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា(គ.រ.រ.) នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៥ រាជរដ្ឋាភិបាលសូមដាក់ចេញនូវសារាចរស្តីពីការកំណត់ និងការអនុវត្តមុខងារនៅតាមក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ (លើកលែងក្រសួងការពារជាតិ និងអង្គភាពដែលទទួលបន្ទុកសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈនៃក្រសួងមហាផ្ទៃ) ដូចខាងក្រោម៖

### ១. ការកំណត់មុខងារតាមវិស័យរបស់ក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័ន ត្រូវធ្វើការកំណត់មុខងាររបស់ខ្លួនឱ្យបានច្បាស់លាស់ ដែលជាមុខងារស្នូលតាមវិស័យ និងមុខងាររងនៃមុខងារស្នូលតាមវិស័យដែលក្រសួង ស្ថាប័នទទួលបន្ទុក។ មុខងារស្នូលតាមវិស័យជាបន្តទៅនេះហៅថា មុខងារស្នូល។ មុខងាររងនៃមុខងារស្នូលតាមវិស័យ ជាបន្តទៅនេះហៅថា មុខងាររងនៃមុខងារស្នូល។

មុខងារស្នូល និងមុខងាររងនៃមុខងារស្នូល គឺជាមូលដ្ឋានផ្តល់សមត្ថកិច្ចដល់ក្រសួង ស្ថាប័នក្នុងការបំពេញមុខងារនិងភារកិច្ច។

ការកំណត់មុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ត្រូវអនុវត្តផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

## ១.១ មុខងារស្នូលរបស់ក្រសួង ស្ថាប័ន

មុខងារស្នូលរបស់ក្រសួង ស្ថាប័ន ជាមុខងារដែលត្រូវបានច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងរាជរដ្ឋាភិបាលកំណត់ និងទទួលស្គាល់ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន ក្នុងវិស័យណាមួយ។

ការកំណត់មុខងារស្នូលរបស់ក្រសួង ស្ថាប័ន ត្រូវផ្អែកលើ៖

- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ច្បាប់ស្តីពីការបង្កើតក្រសួង ស្ថាប័ន
- ច្បាប់ពាក់ព័ន្ធនឹងវិស័យណាមួយដែលក្រសួង ស្ថាប័នទទួលបន្ទុក
- ព្រះរាជក្រឹត្យពាក់ព័ន្ធនឹងការកំណត់សមត្ថកិច្ចដល់ក្រសួង ស្ថាប័ន
- ការសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល។

មុខងារស្នូលរបស់ក្រសួង ស្ថាប័ន ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន ដើម្បីជាមូលដ្ឋាននៃការកំណត់ជាបន្តនូវមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន។

## ១.២ មុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័ន ត្រូវកំណត់មុខងាររងនៃមុខងារស្នូលដោយផ្តើមចេញពីមុខងារស្នូល ដើម្បីឱ្យមានភាពច្បាស់លាស់ក្នុងការអនុវត្តមុខងារដែលជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងជាមូលដ្ឋានសម្រាប់ការកំណត់ជាបន្តនូវរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ព្រមទាំងភារកិច្ចរបស់អង្គភាពនីមួយៗ។

ការកំណត់មុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ត្រូវផ្អែកលើ៖

- មុខងារស្នូលរបស់ក្រសួង ស្ថាប័ន ជាមូលដ្ឋានគោល
- គោលបំណង វិធានការ និងសកម្មភាពជាយុទ្ធសាស្ត្រ ដែលកំណត់នៅក្នុងក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាល រួមមាន៖ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលនយោបាយជាតិតាមវិស័យ, ផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ, ឯកសារក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមានសុពលភាពសម្រាប់នីតិកាលទី៧នៃរដ្ឋសភា, គោលនយោបាយអាទិភាព និងវិធានការគន្លឹះទាំងឡាយរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧នៃរដ្ឋសភា
- គោលបំណង វិធានការ និងសកម្មភាពជាយុទ្ធសាស្ត្រទាំងនេះ ត្រូវផ្សារភ្ជាប់ជាមួយឬជាផ្នែកមួយនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ហើយដែលត្រូវរៀបចំនិងកំណត់ជាមុខងាររងនៃមុខងារស្នូល។

## ១.៣ ភារកិច្ចរបស់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន

ការរៀបចំរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ត្រូវគិតគូរជាមុនអំពីភារកិច្ចដែលអង្គភាពនីមួយៗត្រូវបំពេញ។

ការកំណត់ភារកិច្ចរបស់អង្គភាពទាំងនេះ ត្រូវផ្អែកលើ៖

- មុខងារស្នូលនិងមុខងាររងនៃមុខងារស្នូលដែលជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន

- ក្របខណ្ឌការងារដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ដែលមានកំណត់ក្នុងចំណុច (២) នៃសារាចរនេះ
- មុខងារគាំទ្រដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ដែលមានកំណត់ក្នុងចំណុច (៣) នៃសារាចរនេះ
- មុខងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីធានាថាមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ត្រូវបានអនុវត្តនិងសម្រេចនូវសមិទ្ធកម្មតាមការកំណត់របស់រាជរដ្ឋាភិបាល ដែលមានកំណត់ក្នុងចំណុច (៤) នៃសារាចរនេះ។

## ១.៤ ស្ថានភាពផ្សេងៗនៃការកំណត់មុខងារនិងភារកិច្ច

ស្ថានភាពនៃការត្រួតមុខងារនិងដែនសមត្ថកិច្ច អាចកើតមាននៅកម្រិតមុខងារស្នូល មុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន និងភារកិច្ចរបស់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន។ ទន្ទឹមនេះ ស្ថានភាពមួយចំនួនទៀតក៏អាចកើតឡើង រួមមាន៖ ការកំណត់មុខងារថ្មី មុខងារដែលអនុវត្តមិនមានប្រសិទ្ធភាព មុខងារដែលលែងសមស្រប ការផ្ទេរឬប្រតិភូកម្មមុខងារ ជាដើម។

ការពិនិត្យនិងដោះស្រាយស្ថានភាពទាំងនេះ ត្រូវអនុវត្តផ្អែកលើអភិក្រមការងារដូចខាងក្រោម៖

### ១.៤.១ ការត្រួតមុខងារនិងដែនសមត្ថកិច្ចនៅកម្រិតអន្តរក្រសួង ស្ថាប័ន

ក្នុងករណីមានស្ថានភាពនៃការត្រួតគ្នានៃមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរវាងក្រសួង ស្ថាប័ន ក្រសួងមុខងារសាធារណៈត្រូវធ្វើការសម្របសម្រួលរវាងក្រសួង ស្ថាប័ន ដើម្បីពិនិត្យ ពិភាក្សានិងដោះស្រាយរួមគ្នាអំពីបញ្ហាត្រួតគ្នានៃមុខងារទាំងនេះ និងធ្វើរបាយការណ៍អំពីលទ្ធផលឯកភាពគ្នាជូនប្រមុខរាជរដ្ឋាភិបាលជ្រាប និងផ្តល់ការណែនាំបន្ថែមជាយថាហេតុ។

ក្នុងករណីមិនអាចរកបានការឯកភាពគ្នា ក្រសួងមុខងារសាធារណៈត្រូវលើកបញ្ហានៃការត្រួតគ្នានៃមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

### ១.៤.២ ការត្រួតភារកិច្ចនៅកម្រិតក្នុងក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកក្នុងការរៀបចំនិងកំណត់ភារកិច្ចដល់អង្គភាពក្រោមឱវាទ ដោយធានាមិនឱ្យមានការត្រួតគ្នានៃភារកិច្ចរបស់អង្គភាព។

ភារកិច្ចរបស់អង្គភាព ត្រូវមានភាពច្បាស់លាស់ និងឆ្លើយតបនឹងការអនុវត្តមុខងារស្នូលនិងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន, ព្រមទាំងក្របខណ្ឌការងារ, មុខងារគាំទ្រ, និងមុខងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដែលក្រសួង ស្ថាប័នត្រូវបំពេញ ដើម្បីអនុវត្តមុខងារស្នូលនិងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន។

ក្រសួងមុខងារសាធារណៈ ត្រូវពិនិត្យនិងផ្តល់យោបល់ដល់ក្រសួង ស្ថាប័ន អំពីស្ថានភាពត្រួតភារកិច្ចគ្នារបស់អង្គភាពក្រោមឱវាទរបស់ក្រសួង ស្ថាប័ន ដើម្បីធ្វើការកែលម្អឱ្យបានត្រឹមត្រូវនិងសមស្រប។

### ១.៤.៣ ការកំណត់មុខងារថ្មីបន្ថែម

រាជរដ្ឋាភិបាលអាចកំណត់និងផ្តល់មុខងារថ្មីបន្ថែមដល់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន។

ក្រសួង ស្ថាប័ន ត្រូវពិនិត្យការផ្សារភ្ជាប់មុខងារថ្មីនេះជាមួយនឹងៈ

- មុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ឬ
- ក្របខណ្ឌការងារដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីអនុវត្តមុខងារស្នូលនិងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ឬ
- មុខងារគាំទ្រដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីអនុវត្តមុខងារស្នូលនិងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ឬ
- មុខងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដែលក្រសួង ស្ថាប័នត្រូវបំពេញដើម្បីធានាថាមុខងារស្នូលនិងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ត្រូវបានអនុវត្តនិងសម្រេចនូវសមិទ្ធកម្មតាមការកំណត់របស់រាជរដ្ឋាភិបាល។

មុខងារថ្មីបន្ថែមនេះ អាចត្រូវផ្តល់បន្ថែមដល់អង្គភាពដែលមានស្រាប់ដើម្បីទទួលបន្ទុកអនុវត្ត។

ក្នុងករណីមានមុខងារថ្មីដែលជាមុខងារចាំបាច់ ប៉ុន្តែមិនមានក្រសួង ស្ថាប័នណាមួយទទួលបន្ទុក ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រសួងមុខងារសាធារណៈ ត្រូវលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចក្នុងការប្រគល់មុខងារនេះជូនដល់ក្រសួង ស្ថាប័នណាមួយទទួលបន្ទុកអនុវត្ត។

### ១.៤.៤ មុខងារដែលអនុវត្តមិនមានប្រសិទ្ធភាព

មុខងារដែលត្រូវបានកំណត់និងរៀបចំដោយច្បាស់លាស់ ប៉ុន្តែការអនុវត្តមុខងារនេះមិនមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រសួងមុខងារសាធារណៈ ត្រូវលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចដើម្បីកំណត់និងរៀបចំមុខងារនេះឡើងវិញ ដើម្បីធានាឱ្យការអនុវត្តសម្រេចសមិទ្ធកម្មស្របតាមការកំណត់របស់រាជរដ្ឋាភិបាល។

### ១.៤.៥ មុខងារដែលលែងមានលក្ខណៈសមស្រប

ផ្អែកលើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន មុខងារដែលលែងមានលក្ខណៈសមស្រប ដោយហេតុការផ្លាស់ប្តូរនៃមុខងារស្នូល, មុខងាររងនៃមុខងារស្នូល, គោលនយោបាយ, បច្ចេកវិទ្យា, រចនាសម្ព័ន្ធស្ថាប័ន, ការប្រែប្រួលនៃបរិបទសេដ្ឋកិច្ចសង្គម ជាដើម ក្រសួង ស្ថាប័នត្រូវកែសម្រួល ឬលុបមុខងារនេះចេញ រួមទាំងត្រូវធ្វើការកែសម្រួលរចនាសម្ព័ន្ធអង្គភាព និងមុខងារនិងភារកិច្ចដែលពាក់ព័ន្ធ។

### ១.៤.៦ មុខងារដែលត្រូវប្រគល់ទៅឱ្យក្រសួង ស្ថាប័នផ្សេង

ចំពោះស្ថានភាពដែលក្រសួង ស្ថាប័នកត់សម្គាល់ថា មុខងារដែលក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្ត អាចត្រូវអនុវត្តដោយក្រសួង ស្ថាប័នផ្សេងមានប្រសិទ្ធភាពខ្ពស់ជាង ក្រសួង ស្ថាប័នអាចស្នើសុំរាជរដ្ឋាភិបាលតាមរយៈក្រសួងមុខងារសាធារណៈ ដើម្បីប្រគល់មុខងារនេះដល់ក្រសួង ស្ថាប័នផ្សេងឱ្យទទួលបន្ទុក។

### ១.៤.៧ មុខងារដែលត្រូវបានផ្ទេរ ឬប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

មុខងារដែលត្រូវបានផ្ទេរ ឬប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដោយរាជរដ្ឋាភិបាលឬការសម្រេចរបស់ក្រសួង ស្ថាប័ន ក្រសួង ស្ថាប័នសាមីត្រូវធ្វើការពិនិត្យឡើងវិញ ដើម្បីកំណត់និងរៀបចំមុខងារស្នូល, មុខងាររងនៃមុខងារស្នូលរបស់ខ្លួន ព្រមទាំងភារកិច្ចរបស់អង្គភាពក្រោមឱវាទឱ្យបានសមស្រប។

## ២. ក្របខណ្ឌការងារសម្រាប់ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល

ក្រសួង ស្ថាប័ន ត្រូវពិនិត្យ រៀបចំ និងកំណត់ក្របខណ្ឌការងារឱ្យបានច្បាស់លាស់ ដើម្បីជាមូលដ្ឋាននៃការរៀបចំរចនាសម្ព័ន្ធអង្គភាព, យន្តការស្ថាប័ន, និងប្រព័ន្ធការងារឬវិធីសាស្ត្របំពេញការងារសមស្របផ្សេងៗ ដើម្បីធានាការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័នឱ្យមានប្រសិទ្ធភាព។

ក្របខណ្ឌការងារដែលក្រសួង ស្ថាប័ន ត្រូវបំពេញមានដូចខាងក្រោម៖

### ២.១ ក្របខណ្ឌគោលនយោបាយ

ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកលើក្របខណ្ឌការងារនៃការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន រួមទាំងការបំពេញការងារលើការរៀបចំផែនការយុទ្ធសាស្ត្រ, ក្របខណ្ឌគតិយុត្តនៃការអនុវត្តគោលនយោបាយ, ការស្រាវជ្រាវនិងព្យាករណ៍ផ្នែកគោលនយោបាយ, ការវាយតម្លៃការអនុវត្តគោលនយោបាយ, ការសម្របសម្រួលផ្នែកគោលនយោបាយ និងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីធានាសង្គតិភាព និងសុខដុមនីយកម្មក្នុងការអនុវត្តគោលនយោបាយ។

ក្របខណ្ឌគោលនយោបាយនេះ ត្រូវកំណត់ឱ្យបានជាក់លាក់ដើម្បីតម្រង់ទិស និងកំណត់មូលដ្ឋាននៃវិធានការនិងសកម្មភាពរបស់ក្រសួង ស្ថាប័ន ដើម្បីសម្រេចសមិទ្ធកម្មក្នុងវិស័យ។

មុខងារផ្នែកក្របខណ្ឌគោលនយោបាយអាចត្រូវបំពេញដោយក្រសួង ស្ថាប័ន និងរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន, យន្តការអន្តរស្ថាប័ន ឬយន្តការការងារណាមួយរបស់រាជរដ្ឋាភិបាល។

### ២.២ ក្របខណ្ឌបញ្ញត្តិកម្ម

ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកលើក្របខណ្ឌការងារបញ្ញត្តិកម្មពាក់ព័ន្ធនឹងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន រួមមាន ការកំណត់បែបបទ, វិធីសាស្ត្រ, ការកំណត់និយាម/ស្តង់ដា, ការកំណត់របបគតិយុត្តនៃការធ្វើសកម្មភាពរបស់បុគ្គល, ការផ្តល់សេវា, ការផ្តល់លិខិតអនុញ្ញាត, ការផ្តល់អាជ្ញាបណ្ណ, ការផ្តល់វិញ្ញាបនបត្រ និងការធានាអនុលោមភាពនៃនិយាម/ស្តង់ដា ជាដើម។

ក្របខណ្ឌបញ្ញត្តិកម្មនេះ គឺដើម្បីធានានូវការអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់រូបវន្តបុគ្គល នីតិបុគ្គល និងស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងការការពារនិងថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចនៃការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន។

មុខងារផ្នែកក្របខណ្ឌបញ្ញត្តិកម្ម អាចត្រូវបំពេញដោយក្រសួង ស្ថាប័ន និងរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន, និយ័តករ, ស្ថាប័នរដ្ឋបាលសាធារណៈ, យន្តការអន្តរស្ថាប័ន ឬយន្តការការងារណាមួយរបស់រាជរដ្ឋាភិបាល។

## ២.៣ ក្របខណ្ឌសម្របសម្រួល

ផ្អែកលើអភិក្រម "ដរភាពនៃប្រព័ន្ធតួអង្គតែមួយ" ការសម្របសម្រួលនិងការគាំទ្រគ្នាក្នុងរដ្ឋបាលសាធារណៈ ជាការចាំបាច់ដើម្បីធានាបាននូវការសម្រេចសមិទ្ធកម្មឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជន។

ក្រសួង ស្ថាប័ន ត្រូវបំពេញការងារក្នុងក្របខណ្ឌសម្របសម្រួលនៅកម្រិតអន្តរក្រសួង ស្ថាប័ន និង នៅក្នុងក្រសួង ស្ថាប័នសាមី។ ការសម្របសម្រួលនេះផ្តោតលើការធ្វើសុខដុមនីយកម្ម ការធានាសង្គតិភាព និងការធានាភាពប្រទាក់ក្រឡានិងគាំទ្រគ្នា លើក្របខណ្ឌគោលនយោបាយ វិធានការ សកម្មភាព ព្រមទាំង ការចាត់ចែងនិងប្រើប្រាស់ធនធានមនុស្ស និងថវិកា សំដៅសម្រេចនូវគោលដៅរួមរបស់រាជរដ្ឋាភិបាល។

នៅកម្រិតរាជរដ្ឋាភិបាលនិងអន្តរក្រសួង ស្ថាប័ន ក្រសួង ស្ថាប័នអាចមានតួនាទីក្នុងការដឹកនាំឬ ចូលរួមគាំទ្រឬផ្តល់កិច្ចសហការ ដើម្បីអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ឬអនុវត្តបេសកកម្ម/មុខងារដែលដាក់ចេញដោយរាជរដ្ឋាភិបាល។

ទន្ទឹមនេះ ក្រសួង ស្ថាប័នក៏ត្រូវធានានូវការដឹកនាំសម្របសម្រួលការបំពេញភារកិច្ចរបស់អង្គភាព ក្រោមឱវាទដើម្បីធានាបាននូវការសម្រេចសមិទ្ធកម្មក្នុងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល របស់ក្រសួង ស្ថាប័ន។

## ២.៤ ក្របខណ្ឌផ្តល់សេវា

ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកលើក្របខណ្ឌការងារនៃការផ្តល់សេវាដល់ប្រជាជនពាក់ព័ន្ធនឹងការអនុវត្ត មុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ខ្លួន រួមមាន ការផ្គត់ផ្គង់/ការផ្តល់ផលិតផលឬសេវាដល់អតិថិជន/ អ្នកប្រើប្រាស់សេវា ទាំងក្នុង និងក្រៅក្រសួង ស្ថាប័ន។

ជាធម្មតា ការផ្តល់សេវាសាធារណៈត្រូវអនុវត្តដោយអង្គភាពដែលស្ថិតក្រោមឱវាទឬអាណាព្យាបាល របស់ក្រសួង ស្ថាប័ន ដែលអាចជា អង្គភាពក្រោមឱវាទផ្ទាល់ គ្រឹះស្ថានសាធារណៈរដ្ឋបាល គ្រឹះស្ថានដែល មានស្វ័យភាព ទីភ្នាក់ងារប្រតិបត្តិការពិសេស មន្ទីររាជធានី ខេត្ត ការិយាល័យក្រុង ស្រុក ខណ្ឌ ការិយាល័យ ច្រកចេញចូលតែមួយ ឬអង្គភាពផ្តល់សេវាក្រៅក្រសួង ស្ថាប័ន ជាអាទិ៍។

រចនាសម្ព័ន្ធអង្គភាព ត្រូវផ្តល់ភាពងាយស្រួលក្នុងការទទួលយកសេវា ហើយអង្គភាពទាំងនេះត្រូវ ទទួលបានការផ្តល់នូវសិទ្ធិអំណាចនិងប្រភពធនធានសមស្រប ដើម្បីអាចធានាបាននូវការផ្តល់សេវាប្រកប ដោយគុណភាព ព្រមទាំងឆ្លើយតបនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវា។

# ៣. ការគាំទ្រការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល

ក្រសួង ស្ថាប័ន ត្រូវផ្តល់ការគាំទ្រដល់ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល របស់ក្រសួង ស្ថាប័ន។

ការផ្តល់ការគាំទ្រនេះ ជាការបំពេញមុខងារគាំទ្រដែលក្រសួង ស្ថាប័នត្រូវរៀបចំនិងអនុវត្តឱ្យមាន ប្រសិទ្ធភាព រួមមាន៖ ការរៀបចំដំណើរការផ្នែករដ្ឋបាលនិងហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងនិងអភិវឌ្ឍ ធនធានមនុស្ស, ការគ្រប់គ្រងនិងចាត់ចែងហិរញ្ញវត្ថុសាធារណៈ, ផែនការនិងស្ថិតិ, និងការរៀបចំនិងអនុវត្ត ប្រព័ន្ធសវនកម្មផ្ទៃក្នុង។

ដើម្បីធានាសង្គតិភាព និងស្តង់ដារួមសម្រាប់គ្រប់ក្រសួង ស្ថាប័ន ការកំណត់ភារកិច្ចរបស់អង្គភាពដែលបំពេញមុខងារគាំទ្រ និងការកំណត់មុខតំណែងមន្ត្រីអនុវត្តមុខងារគាំទ្រ ត្រូវទទួលបន្ទុករៀបចំដោយក្រសួង ស្ថាប័ន ដូចខាងក្រោម ៖

– មុខងាររដ្ឋបាល និងធនធានមនុស្ស ត្រូវទទួលបន្ទុករៀបចំដោយក្រសួងមុខងារសាធារណៈ
– មុខងារហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្នុង ត្រូវទទួលបន្ទុករៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
– មុខងារផែនការនិងស្ថិតិ ត្រូវទទួលបន្ទុករៀបចំដោយក្រសួងផែនការ។

ក្រសួង ស្ថាប័នទទួលបន្ទុក ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការកំណត់ភារកិច្ចរបស់អង្គភាព និងមុខតំណែងមន្ត្រីអនុវត្តមុខងារគាំទ្រ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ អាចកំណត់ភារកិច្ច និងមុខតំណែងមន្ត្រីបន្ថែម សម្រាប់ការអនុវត្តមុខងារគាំទ្រផ្អែកលើស្ថានភាពនិងវិសេសភាពនៃក្រសួង ស្ថាប័ន ដោយត្រូវពិគ្រោះយោបល់ជាមួយក្រសួងទទួលបន្ទុកខាងលើ។

ភារកិច្ចរបស់អង្គភាពដែលបំពេញមុខងារគាំទ្រផ្សេងទៀត ព្រមទាំងការកំណត់មុខតំណែងមន្ត្រីអនុវត្តមុខងារគាំទ្រទាំងនោះ ត្រូវអនុវត្តផ្អែកលើការសម្រេចរបស់គណៈកម្មាធិការជាតិដឹកនាំការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

ភារកិច្ចរបស់អង្គភាពបំពេញមុខងារគាំទ្រ និងមុខតំណែងមន្ត្រី ត្រូវកំណត់ដោយអនុក្រឹត្យ។

## ៤. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល

ក្រសួង ស្ថាប័ន ត្រូវរៀបចំឱ្យមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងផ្តល់ការគាំទ្រ និងសម្របសម្រួលនានា ដើម្បីធានានូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល។

ការរៀបចំប្រព័ន្ធនេះ ត្រូវផ្សារភ្ជាប់ជាមួយៈ

– ក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល
– សូចនាករសមិទ្ធកម្មក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី
– កិច្ចព្រមព្រៀងសមិទ្ធកម្មរវាងក្រសួង ស្ថាប័នសាមី ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
– កិច្ចព្រមព្រៀងសមិទ្ធកម្មរវាងប្រធានស្ថាប័ន ជាមួយអង្គភាពក្រោមឱវាទ។

ក្នុងន័យនេះ ក្រសួង ស្ថាប័នត្រូវទទួលខុសត្រូវនិងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល លើសមិទ្ធកម្មក្នុងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ខ្លួន។ ក្រសួង ស្ថាប័ន ត្រូវតាមដានត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពការងាររបស់ខ្លួន និងសមិទ្ធកម្មសម្រេចបានធៀបនឹងសូចនាករសមិទ្ធកម្មកំណត់ដោយរាជរដ្ឋាភិបាល។

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនេះ ក៏នឹងជួយដល់ក្រសួង ស្ថាប័ន និងរាជរដ្ឋាភិបាល ក្នុងការពិនិត្យនិងកំណត់ការបែងចែកនិងការប្រើប្រាស់ធនធានមនុស្ស និងថវិកា ព្រមទាំងការរៀបចំយន្តការការងារឱ្យបានសមស្របដើម្បីលើកកម្ពស់សមិទ្ធកម្មកាន់តែប្រសើរ។

## ៥. មុខងារនិងការរៀបចំរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង ស្ថាប័ន ត្រូវអនុវត្តផ្អែកលើមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន, ក្របខណ្ឌការងារសម្រាប់ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល, មុខងារគាំទ្រ, ព្រមទាំងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល។

ក្នុងន័យនេះ ការរៀបចំរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នត្រូវគិតគូរឈរលើគោលការណ៍ដូចខាងក្រោម៖

### ៥.១ អភិក្រមនៃការរៀបចំរចនាសម្ព័ន្ធ

នៅក្នុងការរៀបចំរចនាសម្ព័ន្ធអង្គភាព ក្រសួង ស្ថាប័ន ត្រូវធានាឱ្យបាននូវការគោរពអភិក្រមការងារដូចខាងក្រោម៖

- ការរៀបចំរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នឱ្យរៀបរយ ដោយធានាឱ្យបាននូវការអនុវត្តមុខងារពិតប្រាកដ ព្រមទាំងអភិក្រមនិងវិធីការងារក្នុង និងក្រៅក្រសួង ស្ថាប័នឱ្យមានប្រសិទ្ធភាពខ្ពស់, កាន់តែសាមញ្ញ, ប្រើពេលវេលាកាន់តែឆាប់រហ័ស, ចំណាយធនធានថវិកាទាបជាងមុន, និងប្រើប្រាស់ធនធានមនុស្សអស់សក្តានុពល
- ការពង្រឹងរចនាសម្ព័ន្ធស្ថាប័នជាជាងពង្រីករចនាសម្ព័ន្ធស្ថាប័ន ដែលនាំឱ្យប៉ះពាល់ដល់បន្ទុកថវិកា និងបន្ទុកបុគ្គលិក ដោយត្រូវពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធទាំងមូលនិងវិធីការងាររួមរបស់ក្រសួង ស្ថាប័ន។

### ៥.២ ការរៀបចំរចនាសម្ព័ន្ធដោយផ្សារភ្ជាប់ជាមួយនឹងការអនុវត្តមុខងារ

ក្រសួង ស្ថាប័ន ត្រូវពិនិត្យ និងរៀបចំរចនាសម្ព័ន្ធអង្គភាពឱ្យមានដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយផ្អែកលើ៖

- ការឆ្លើយតបនឹងមុខងារនិងទំហំការងារ
- ការផ្តល់មុខងារបន្ថែមដល់អង្គភាពដែលមានស្រាប់ ជាជាងការបង្កើតអង្គភាពថ្មីឱ្យទទួលបន្ទុក ឬដំឡើងកម្រិតអង្គភាពដែលមានស្រាប់
- ការលុបអង្គភាពដែលមានភារកិច្ចមិនស្របនឹងមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល
- ការច្របាច់បញ្ចូលគ្នានូវរចនាសម្ព័ន្ធដែលបំពេញភារកិច្ចដូចគ្នា ឬអង្គភាពដែលមិនមានដំណើរការឬដំណើរការមិនមានប្រសិទ្ធភាព ដោយពិនិត្យទាំងក្នុងក្របខណ្ឌក្រសួង ស្ថាប័ន និងយន្តការការងារអន្តរក្រសួង ស្ថាប័ន ដែលក្រសួង ស្ថាប័នទទួលបន្ទុក
- ការប្រើប្រាស់រចនាសម្ព័ន្ធអង្គភាពរបស់ក្រសួង ស្ថាប័ន ដើម្បីគាំទ្រដល់យន្តការការងារអន្តរក្រសួង ស្ថាប័ន ដែលទទួលបន្ទុកអនុវត្តដឹកនាំនិងសម្របសម្រួលការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ជាជាងការបង្កើតរចនាសម្ព័ន្ធថ្មីដោយឡែក ដើម្បីគាំទ្រដល់យន្តការការងារអន្តរក្រសួង ស្ថាប័ន។

### ៥.២.១ ការរៀបចំរចនាសម្ព័ន្ធអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល

ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ត្រូវគិតគូរផ្អែកលើក្របខណ្ឌការងារ រួមមាន ក្របខណ្ឌគោលនយោបាយ, ក្របខណ្ឌបញ្ញត្តិកម្ម, ក្របខណ្ឌសម្របសម្រួល, ក្របខណ្ឌផ្តល់សេវា និងការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ការរៀបចំរចនាសម្ព័ន្ធឬយន្តការការងារ ក្នុងក្របខណ្ឌការងារដើម្បីអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ត្រូវឆ្លើយតបនឹងទំហំការងារ ព្រមទាំងធានាបាននូវប្រសិទ្ធភាពការងារខ្ពស់។

ការរៀបចំរចនាសម្ព័ន្ធនិងយន្តការការងារ ត្រូវគិតគូរផ្អែកលើ៖

- រចនាសម្ព័ន្ធក្នុងកម្រិតអគ្គនាយកដ្ឋាន នាយកដ្ឋាន ឬក្រោមនាយកដ្ឋាន ឱ្យឆ្លើយតបនឹងទំហំនៃការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល
- ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការបំពេញការងារក្នុងក្របខណ្ឌគោលនយោបាយ, ក្របខណ្ឌបញ្ញត្តិកម្ម, ក្របខណ្ឌសម្របសម្រួល, ក្របខណ្ឌផ្តល់សេវា និងការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ដោយប្រើប្រាស់យន្តការ រួមមាន យន្តការអន្តរក្រសួង គ្រឹះស្ថាន ក្រុមការងារបច្ចេកទេស គណៈកម្មការ និងយន្តការការងារសមស្របផ្សេងទៀត
- ការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ដែលអាចប្រើប្រាស់សមត្ថភាពពីខាងក្រៅ។

### ៥.២.២ ការរៀបចំរចនាសម្ព័ន្ធដើម្បីអនុវត្តមុខងារគាំទ្រ

ក្រសួង ស្ថាប័ន ត្រូវរៀបចំរចនាសម្ព័ន្ធដើម្បីអនុវត្តមុខងារគាំទ្រដល់មុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន ដូចខាងក្រោម៖

- រចនាសម្ព័ន្ធត្រូវរៀបចំឱ្យបានសមស្របទៅតាមទំហំនិងវិសេសភាពនៃការងាររបស់ក្រសួង ស្ថាប័ននីមួយៗ
- ក្រសួង ស្ថាប័នក៏អាចប្រើប្រាស់យន្តការក្រៅក្រសួង ស្ថាប័ន ដើម្បីបំពេញមុខងារគាំទ្រ ក្នុងករណីដែលការប្រើប្រាស់បែបនេះអាចសម្រេចបានសមិទ្ធកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយប្រើពេលវេលាតិច និងចំណាយទាបជាងការរៀបចំឱ្យមានរចនាសម្ព័ន្ធអង្គភាពនៅក្នុងក្រសួង ស្ថាប័ន ព្រមទាំងមិនបង្កើតបន្ទុកដែលមិនចាំបាច់ជាលក្ខណៈអចិន្ត្រៃយ៍។

### ៥.២.៣ ការទទួលខុសត្រូវ និងគណនេយ្យភាព

ក្រសួង ស្ថាប័ន ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីការទទួលខុសត្រូវនិងគណនេយ្យភាពរបស់មន្ត្រីដែលទទួលបន្ទុកបំពេញតួនាទីនិងភារកិច្ចនៅក្នុងរចនាសម្ព័ន្ធអង្គភាពរបស់ក្រសួង ស្ថាប័ន ដែលធានានូវការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន។

## ៦. មុខងារនិងការប្រើប្រាស់ធនធានមនុស្ស

ក្រសួង ស្ថាប័ន ត្រូវកំណត់មុខតំណែងនិងប្រើប្រាស់មុខតំណែងជាក់លាក់ ដើម្បីរៀបចំនិងអនុវត្តផែនការនៃការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សរបស់ខ្លួន។

មុខងារស្នូល និងមុខងាររងនៃមុខងារស្នូល, ក្របខណ្ឌការងារក្នុងការអនុវត្តមុខងារស្នូលនិងមុខងាររងនៃមុខងារស្នូល, មុខងារគាំទ្រ ព្រមទាំងមុខងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការកំណត់មុខតំណែង ការពិពណ៌នាមុខតំណែង និងគុណវុឌ្ឍិនៃមុខតំណែងមន្ត្រី។

ប្រសិនបើក្រសួង ស្ថាប័នមិនបានកំណត់មុខតំណែងជាក់លាក់ ឆ្លើយតបនឹងតម្រូវការនៃមុខងារ និងក្របខណ្ឌការងារ ក្រសួង ស្ថាប័នមិនត្រូវបានអនុញ្ញាតឱ្យជ្រើសរើសមន្ត្រីថ្មីបន្ថែមទៀតឡើយ។

## ៧. មុខងារនិងការប្រើប្រាស់ថវិកា

ការវិភាជ និងប្រើប្រាស់ថវិកា ត្រូវឆ្លើយតបនឹងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូល ដោយសម្រេចឱ្យបាននូវសូចនាករសមិទ្ធកម្មដែលបានកំណត់។

ការប្រើប្រាស់ថវិកា ដើម្បីលើកទឹកចិត្តគាំទ្រសមិទ្ធកម្មនៅតាមក្រសួង ស្ថាប័ន ត្រូវផ្អែកលើមូលដ្ឋាននៃសូចនាករសមិទ្ធកម្ម ដែលត្រូវកំណត់ឆ្លើយតបនឹងការអនុវត្តមុខងារស្នូល និងមុខងាររងនៃមុខងារស្នូលរបស់ក្រសួង ស្ថាប័ន។

## ៨. ការផ្តល់ការគាំទ្រ

ក្រសួងមុខងារសាធារណៈ ត្រូវផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័នក្នុងការកំណត់ និងការអនុវត្តមុខងារ និងការរៀបចំរចនាសម្ព័ន្ធស្របតាមខ្លឹមសារនៃសារាចរនេះ។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២៥
នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ